# Registration, Approval, and License for General Insurance Company

LEGAL & TAX ADVISORS

CAMBODIA SEYCHELLES

**Cambodia**
No. 176Z , Street 370,
Phnom Penh, Kingdom of Cambodia

**Seychelles**
Room 13, Oceangate House,
P.O. Box 203,
Victoria, Mahe, Seychelles

info@pa-asia.net
www.pa-asia.net

P&A | ASIA
LEGAL & TAX ADVISORS

# ឯកសារតម្រូវសំរាប់ការស្នើសុំអាជ្ញាប័ណ្ណធានារ៉ាប់រងទូទៅ

## I- សំរាប់ការស្នើសុំឯកភាពជាគោលការណ៍ "1G"

1. លិខិតស្នើសុំ
(Letter Of Intent)
2. អធិប្បាយសង្ខេបនៃអាជីវកម្មរបស់ក្រុមហ៊ុន ដែលកំពុងមានប្រតិបត្តិការនៅលើពិភពលោក
(Brief Description of Company Existing Worldwide Operation)
3. ព័ត៌មានចុងក្រោយអំពីការផ្តល់ចំណាត់ថ្នាក់ដល់សម្ព័ន្ធក្រុមហ៊ុន
(Latest Credit Rating Information of the Group Company)
4. រចនាសម្ព័ន្ធក្រុមហ៊ុននៃសម្ព័ន្ធក្រុមហ៊ុន (បើមាន)
(Structure of the group, if any)
5. របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចនៃក្រុមហ៊ុនសម្ព័ន្ធសំរាប់រយៈពេល ០៣ ឆ្នាំចុងក្រោយ
(Audited Financial Reports of the Group for last 3 years)
6. រចនាសម្ព័ន្ធនៃក្រុមហ៊ុនស្នើសុំអាជ្ញាបណ្ណ
(Structure of the Company)
7. របាយការណ៍ស្តីអំពីភាពអាចធ្វើទៅបាន និងរបាយការណ៍វិភាគទីផ្សារ និងពត៌មានលម្អិតអំពីការស្រាវជ្រាវលើអតិថិជន
(Feasibility and Market Analysis Report, and Details of Customers Research)
8. ផែនការអាជីវកម្ម រួមទាំង ផលត្រឡប់បានមកពីអាជីវកម្ម និងរយៈពេលស្រង់ដើម
(Business Plan includes IRR and Payback Period)
9. ប្រភពធនធាន រួមទាំង ការវិនិយោគ និង គោលនយោបាយគ្រប់គ្រងមូលធន
(Source of Fund including Investment and Capital Management Policy)
10. បញ្ជាក់អំពីគុណវុឌ្ឍិរបស់បុគ្គលដែលត្រូវតែងតាំងជាអ្នកត្រួតពិនិត្យហានិភ័យធានារ៉ាប់រង(បើមាន) សមាសភាពក្រុមប្រឹក្សាភិបាល នាយកគ្រប់គ្រង ឬនាយកប្រតិបត្តិ និងអ្នកគ្រប់គ្រងសំខាន់ៗ។ ឯកសារតម្រូវរួមមានដូចជា÷ ប្រវត្តិរូបសង្ខេប ច្បាប់ថតចម្លងសញ្ញាបត្រ ឬវិញ្ញាបនបត្រជំនាញ ច្បាប់ថតចម្លងលិខិតឆ្លងដែន ឬអត្តសញ្ញាណបណ្ណ។
(Qualification of appointed loss adjuster (if any) or underwriter, Board of Directors, Chief Executive Officer/General Manager. Document should be required: curriculum vitae, copy of certificate/ diploma, copy of passport / ID card.)
11. ផែនការបណ្តុះបណ្តាល
(Training Program)

## II- សំរាប់ទទួលបានអជ្ញាបណ្ណប្រកបអាជីវកម្ម “2G”

### ១. សេចក្តីអធិប្បាយសង្ខេបលើដំណើរការអាជីវកម្មជាសាកលរបស់ក្រុមហ៊ុន

☐ ១.១ ផ្តល់នូវប្រវត្តិសង្ខេបរបស់ក្រុមហ៊ុនសម្ព័ន្ធក្រុមហ៊ុននិងក្រុមហ៊ុនមេ (រួមទាំងកាលបរិច្ឆេទ ទីកន្លែងនៃសាជីវកម្មការចុះបញ្ជីក្នុងទីផ្សារមូលបត្រណាមួយនិងចំនួនបុគ្គលិកក្រុមហ៊ុន)។

☐ ១.២ ផ្តល់រចនាសម្ព័ន្ធនៃសម្ព័ន្ធក្រុមហ៊ុន។

☐ ១.៣ ផ្តល់ឈ្មោះសញ្ជាតិអាសយដ្ឋាននៃភាគទុនិកដែលមានកាន់ភាគហ៊ុន។

☐ ១.៤ ផ្តល់ឈ្មោះក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនធានារ៉ាប់រងបន្ត និងអន្តរការីធានារ៉ាប់រង។

☐ ១.៥ ពណ៌នាអំពីក្រុមហ៊ុនធានារ៉ាប់រង និងប្រភេទផលិតផល ឬសេវាហិរញ្ញវត្ថុ។

☐ ១.៦ ផ្តល់ព័ត៌មានស្តីអំពីចំណាត់ថ្នាក់របស់ក្រុមហ៊ុន និងសម្ព័ន្ធក្រុមហ៊ុននៅក្នុងប្រទេសដើម និងក្នុងសកលលោកដោយយោងទៅលើ ÷

☐១.៦.១ ទ្រព្យសកម្ម បុព្វលាភដុល និងបុព្វលាភសុទ្ធ និងទឹកប្រាក់ត្រូវបានធានារ៉ាប់រង

☐១.៦.២ ស្ថានភាពហិរញ្ញវត្ថុដែលមានការវាយតម្លៃដោយក្រុមហ៊ុន Standard &Poor’s(S&P) ឬចំណាត់ថ្នាក់សមមូលរបស់ភ្នាក់ងារចាត់ថ្នាក់ដែលទទួលស្គាល់ជាអន្តរជាតិ។

☐ ១.៧ របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចក្នុងរយៈពេល ៣ (បី) ឆ្នាំកន្លងមកសំរាប់សម្ព័ន្ធក្រុមហ៊ុន។

☐ ១.៨ គោលការណ៍អភិបាលកិច្ច។

☐ ១.៩ គោលការណ៍ណែនាំគណនេយ្យ។

### ២. ពណ៌នាអំពីផែនការប្រតិបត្តិការអាជីវកម្ម ÷ សូមផ្តល់ជូនផែនការអាជីវកម្មរយៈពេល ៣ (បី) ឆ្នាំ សម្រាប់ប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា ដោយរួមមាន ÷

☐២.១ សូមផ្តល់នូវរចនាសម្ព័ន្ធនិងផែនការស្តីពីធនធានមនុស្ស។សូមបង្ហាញពីចំនួនបុគ្គលិកដែលក្រុមហ៊ុនត្រូវមាន (បុគ្គលិកបរទេស និង បុគ្គលិកក្នុងស្រុក) និងគោលនយោបាយបណ្តុះបណ្តាលធនធានមនុស្ស។

☐២.២ ផែនការអាជីវកម្មសម្រាប់រយៈពេល ៣ ឆ្នាំ។

☐២.២.១ យុទ្ធសាស្ត្រអាជីវកម្មដោយលំអិតពីបណ្តាញផ្តល់សេវាកម្ម (ជើងសាធានារ៉ាប់រងនិងភ្នាក់ងារធានារ៉ាប់រង) និងលំអិតពីព័ត៌មាននៃគោលដៅទីផ្សារ។

☐២.២.២ ផែនការហិរញ្ញវត្ថុសម្រាប់រយៈពេល ៣ ឆ្នាំ÷

☐២.២.២.១ ផែនការចំណូលពីអាជីវកម្មថ្មី (New volume of business) ដោយមានបង្ហាញ

P&A | ASIA
LEGAL & TAX ADVISORS

នូវប្រភេទកិច្ចសន្យាធានារ៉ាប់រងថ្មីៗ។

☐២.២.២.២ ផែនការចំណូលដែលបានពីកិច្ចសន្យាមានស្រាប់ (In-force business performance) ដោយមានបង្ហាញនូវប្រភេទកិច្ចសន្យា។

☐២.២.២.៣ របាយការណ៍លំហូរសាច់ប្រាក់

☐២.២.២.៤ គណនីចំណេញ- ខាត

☐២.២.២.៥ តារាងតុល្យការ

☐២.២.២.៦ ដើមទុន ប្រាក់សាធនភាព និងគោលការណ៍គ្រប់គ្រងទ្រព្យសកម្ម

☐២.២.២.៧ ភាគលាភសម្រាប់ម្ចាស់ភាគហ៊ុន

☐២.២.២.៨ រយៈពេលស្រង់ដើម និងផលបានមកពីអាជីវកម្ម

☐២.២.២.៩ កាលបរិច្ឆេទនៃការបិទបញ្ជីហិរញ្ញវត្ថុរបស់ក្រុមហ៊ុនធានារ៉ាប់រង

**៣. ផ្តល់ព័ត៌មានស្តីពីកិច្ចព្រមព្រៀងធានារ៉ាប់រងបន្តការកំណត់តម្លៃនិងវិភាគហានិភ័យ វិធីសាស្ត្រទប់ស្កាត់នឹងការសំអាតប្រាក់ និងប្រព័ន្ធគ្រប់គ្រងហានិភ័យផ្សេងទៀតប្រសិនបើមាន។**

**៤. ឯកសារដែលបានចុះបញ្ជីនៅក្នុងប្រទេសកម្ពុជា**

☐៤.១ ច្បាប់ចម្លងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងក្រុមហ៊ុនដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មនៅកម្ពុជា។

☐៤.២ បញ្ជាក់ពីទីតាំងប្រតិបត្តិការ ឬគ្រោងនឹងប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា។

**៥. ឯកសារពីប្រទេសដើម**

☐៥.១ ច្បាប់ចម្លងវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីក្រុមហ៊ុន ដែលចេញដោយអាជ្ញាធរប្រទេសដើម។

☐៥.២ អាជ្ញាបណ្ណធានារ៉ាប់រងថតចំលងដែលចេញដោយអាជ្ញាធរគ្រប់គ្រងធានារ៉ាប់រងនៅប្រទេសដើម។

☐៥.៣ លិខិតបញ្ជាក់ពីអាជ្ញាធរគ្រប់គ្រងធានារ៉ាប់រងនៅប្រទេសដើមដែលអនុញ្ញាតឱ្យបង្កើតក្រុមហ៊ុន ឬ សាខាធានារ៉ាប់រងនៅកម្ពុជា ប្រសិនបើមានច្បាប់តម្រូវ។ សូមភ្ជាប់លិខិតបញ្ជាក់ពីអាជ្ញាធរប្រសិនបើមិនមានការតម្រូវទាមទារពីច្បាប់នៃប្រទេសដើម។

☐៥.៤ សូមបញ្ជាក់ពីច្បាប់កម្រិតមួយចំនួនរបស់រដ្ឋាភិបាលនៅប្រទេសដើមអំពី ចលនាដើមទុន អត្រាប្តូរប្រាក់ និងសិទ្ធិធ្វើអាជីវកម្មនៅកម្ពុជាជាដើម។

☐៥.៥ ច្បាប់ចម្លងឯកសារត្រួតពិនិត្យចុងក្រោយដែលចេញដោយអាជ្ញាធរគ្រប់គ្រងនៃប្រទេសដើម។

**៦. ឯកសារតម្រូវសម្រាប់ក្រុមប្រឹក្សាភិបាល នាយកប្រតិបត្តិ និងអ្នកគ្រប់គ្រងសំខាន់ៗ**

☐៦.១ សេចក្តីសម្រេចនៃការបង្កើតសាខាក្រុមហ៊ុនធានារ៉ាប់រងនៅក្នុងប្រទេសកម្ពុជា។

☐៦.២ សេចក្តីសម្រេចនៃការតែងតាំងបុគ្គលដែលមានគុណវុឌ្ឍិជាអ្នកគ្រប់គ្រងក្រុមហ៊ុនធានារ៉ាប់រងនៅក្នុងប្រទេសកម្ពុជា។

☐៦.៣ ផ្តល់នូវប្រវត្តិរូបសង្ខេប ច្បាប់ថតចម្លងសញ្ញាបត្រ វិញ្ញាបនបត្រជំនាញ លិខិតថ្កោលទោស ច្បាប់ថតចម្លងអត្តសញ្ញាណប័ណ្ណ ឬ ច្បាប់ថតចម្លងលិខិតឆ្លងដែន (ជនបរទេស) កិច្ចសន្យាការងារ សៀវភៅការងារ និងរូបថត ៤*៦ ចំនួន ៣ សន្លឹក (សម្រាប់ប្រធានក្រុមប្រឹក្សាភិបាល)។

☐៦.៤ សំរាប់បុគ្គលិកបរទេសត្រូវផ្តល់ជូននូវច្បាប់ចម្លងលិខិតឆ្លងដែន និងសៀវភៅការងារ។

☐៦.៥ ផ្តល់នូវព័ត៌មានស្តីពីក្រុមហ៊ុនត្រួតពិនិត្យហានិភ័យធានារ៉ាប់រង (បើមាន)

☐៦.៦ សវនកម្មផ្ទៃក្នុង

☐៦.៦.១ រចនាសម្ព័ន្ធ និងសមាសភាព នៃនាយកដ្ឋានសវនកម្មផ្ទៃក្នុង

☐៦.៦.២ ឈ្មោះ អាសយដ្ឋាន និងគុណវុឌ្ឍិនៃសវនករផ្ទៃក្នុងក្រុមហ៊ុនធានារ៉ាប់រង

☐៦.៦.៣ នីតិវិធីសវនកម្មផ្ទៃក្នុងដែលបានបង្កើតឡើង និងដំណើរការដើម្បីធានាបានជាមួយនឹងក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិនៃច្បាប់ស្តីពីការធានារ៉ាប់រង។

**៧. ធនាគារបង្គោល÷** ឈ្មោះ និងអាសយដ្ឋានរបស់ធនាគារបង្គោល។

**៨. ផលិតផល**

☐៨.១ បញ្ជាក់ពីផលិតផល និងសេវាធានារ៉ាប់រងដែលត្រូវផ្តល់នៅក្នុងប្រទេសកម្ពុជាក្នុងដំណាក់កាលដំបូង

☐៨.២ គំរូបណ្ណសន្យារ៉ាប់រង កិច្ចសន្យាបន្ថែមទម្រង់បែបបទ ឯកសារលក់ និងលិខិតបោះពុម្ពសំរាប់ចែកផ្សាយដល់សាធារណជន ទៅតាមប្រភេទប្រតិបត្តិការនីមួយៗ។

**៩. ដើមទុន**

☐៩.១ ដើមទុន ៧ ០០០ ០០០ (ប្រាំពីលាន)ដុល្លារ

☐៩.២ ប្រាក់កំរិតសាធនភាពអប្បបរមា ៣ ៥០០ ០០០ (បីលានប្រាំសែន)ដុល្លារ រក្សាទុកនៅធនាគារពាណិជ្ជណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា។

☐៩.៣ ប្រាក់តំកល់ ៧០០ ០០០ (ប្រាំពីររយពាន់) ដុល្លារ ឬ ១០%នៃដើមទុន ដើម្បីរក្សាទុកក្នុងគណនីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅធនាគារជាតិនៃកម្ពុជា។

☐៩.៤ កម្រៃអាជ្ញាប័ណ្ណ ៥០ ០០០ ០០០ (ហាសិបលាន)រៀលក្នុងគណនីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅធនាគារជាតិនៃកម្ពុជា។